**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០១១ ២៤៣ ប្រ.ក

# ប្រកាស
## ស្តីពី
## តម្លាភាពក្នុងការផ្តល់សេវាឥណទាន របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ការផ្តល់សេវាឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រកបដោយតម្លាភាព យុត្តិធម៌ សមហេតុផល និងទទួលខុសត្រូវ។

**ប្រការ ២.-**

គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធានាថាការផ្សព្វផ្សាយពាណិជ្ជកម្ម និងពាក្យពេចន៍ក្នុងការផ្សព្វផ្សាយមានលក្ខណៈយុត្តិធម៌ ច្បាស់លាស់ មិនធ្វើឲ្យភាន់ច្រឡំ និងត្រូវធានាថាអតិថិជនបានទទួលព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣.-**

អតិថិជនត្រូវទទួលបានព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មទាំងឡាយ នៅមុនពេល
ឬក្នុងពេល ឬបន្ទាប់ពីពេលទទួលសេវាឥណទាន ដោយរួមមានបែបបទដំណើរការនៃឥណទាន លក្ខខណ្ឌ
អត្រាការប្រាក់ និងកម្រៃដែលជាបន្ទុករបស់អតិថិជន ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.-**

អតិថិជនត្រូវទទួលបានព័ត៌មានជាមុន អំពីការប្រែប្រួលអត្រាការប្រាក់ កម្រៃ និងលក្ខខណ្ឌផ្សេងៗ។

**ប្រការ ៥.-**

ព័ត៌មានអតិថិជនត្រូវបានរក្សាទុកជាការសម្ងាត់ ហើយគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្តល់
ជូនអតិថិជននូវប្រព័ន្ធធនាគារស្នូល និងប្រព័ន្ធទូទាត់ដែលមានសុវត្ថិភាព និងអាចជឿទុកចិត្តបាន។ ការរក្សា
ព័ត៌មានអតិថិជនជាសម្ងាត់មិនត្រូវអនុវត្តចំពោះការផ្តល់ព័ត៌មានអតិថិជនដល់ប្រព័ន្ធព័ត៌មានឥណទាននោះទេ។

**ប្រការ ៦.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន
អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិង
ហិរញ្ញវត្ថុ នៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗ
ខ្លួន។

**ប្រការ ៧.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

ជា-ចាន់តូ

**កន្លែងទទួល** :

- ដូចប្រការ ៦
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន** :

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

# តារាងព័ត៌មានសម្រាប់អតិថិជន

តារាងនេះសម្រាប់ផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ តារាងនេះកំណត់ចេញនូវថ្លៃដើមពេលបច្ចុប្បន្ន និងកម្រៃផ្សេងៗសម្រាប់ឥណទានដែលទទួលបាន ហើយធនាគារអាចកែប្រែថ្លៃដើម និងកម្រៃទាំងនេះ ក្នុងករណីចាំបាច់។ សូមមេត្តាកត់សំគាល់ថា ការផ្តល់នូវតារាងនេះមិនត្រូវចាត់ទុកថាជាការផ្តល់ឥណទានដល់អតិថិជនដោយធនាគារនោះទេ។

ឈ្មោះធនាគារ/និមិត្តសញ្ញា

ឈ្មោះអ្នកសួរព័ត៌មាន ____________________

១. សាខា ____________________

ប្រភេទនៃខ្ទង់ឥណទាន ____________________

**ចំនួនឥណទាន និងការប្រាក់/កម្រៃផ្សេងៗរបស់ធនាគារ**

(គិតជាប្រាក់រៀល)

២. ចំនួនស្នើសុំ(ចំនួនប្រាក់ដើម) __________

៣. (ដក: ចំនួនត្រូវទូទាត់ក្នុងគ្រាទី១/ការប្រាក់បានបង់មុន) __________

៤. ចំនួនសុទ្ធដែលអតិថិជនបានទទួល __________

៥. អត្រាដែលស្នើសុំ ________%ក្នុង១ឆ្នាំ

៦. អត្រាការប្រាក់មានប្រសិទ្ធភាព ________%ក្នុង១ឆ្នាំ

៧. ការទូទាត់ប្រចាំខែ __________

៨. ចំនួនដងដែលត្រូវទូទាត់សង __________

៩. ការប្រាក់សរុប __________

១០.កម្រៃធ្វើប្រតិបត្តិការ __________

១១.កម្រៃផ្សេងៗរបស់ធនាគារ (សូមបញ្ជាក់ ប្រសិនបើមាន)

____________________________________ __________

១២. កម្រៃផ្សេងៗសរុប (ជួរទី១០ + ជួរទី១១) __________

១៣. ការប្រាក់សរុបបូកកម្រៃផ្សេងៗសរុប (ជួរទី៩ + ជួរទី១២) __________

១៤. សរុបចំនួននៅជំពាក់ (ជួរទី២ + (៣) ឬជួរទី៤ + ជួរទី១៣) __________

១៥. កាលបរិច្ឆេទនៃការចាប់ផ្តើមទូទាត់សង ______________________________

**<u>កម្រៃបន្ថែម</u>**

ធនាគារនឹងគិតកម្រៃសម្រាប់

| | | |
|---|---|---|
| **(ក) ការទូទាត់សងឥណទានមុនពេលកំនត់** | ការទូទាត់សងដោយផ្នែក | ការទូទាត់សងពេញលេញ |
| ១៦.ប្រសិនបើសងក្នុងកំឡុងពេល | ______ឆ្នាំ | ______ឆ្នាំ |
| ១៧.ចំនួននៃការទូទាត់សងអប្បបរមាគឺ | ______ | |
| ១៨.កម្រៃលើការទូទាត់សងមុនពេលកំណត់ | ______ | ______ |
| ១៩.កម្រៃធ្វើប្រតិបត្តិការ | ______ | ______ |
| ២០.កំឡុងពេលជូនដំណឹងដែលតម្រូវ | ______ | ______ |

**(ខ) ការទូទាត់យឺតយ៉ាវតាមគ្រានិមួយៗ**

| | |
|---|---|
| ២១.ការប្រាក់ដែលត្រូវគិតគឺ | ______ %ក្នុង១ឆ្នាំ (សម្រាប់ចំនួនដែលជំពាក់) |
| ២២.កម្រៃធ្វើប្រតិបត្តិការ | ______ |
| ២៣.កម្រៃផ្សេងៗ | ______ |

**<u>កម្រៃសម្រាប់តតិយជន</u>**

២៤. ព័ត៌មានខាងលើ មិនរាប់បញ្ចូលកម្រៃសម្រាប់តតិយជន មានដូចជាតែមប្រ៏ កម្រៃផ្នែកច្បាប់ កម្រៃលើការវាយតំលៃ បុព្វលាភធានារ៉ាប់រង។ល។ សូមមេត្តាត្រួតពិនិត្យជាមួយគូរភាគីខាងលើស្តីពីកម្រៃទាំងឡាយ។

**គោលនយោបាយធានារ៉ាប់រងដែលទាមទារឲ្យមាន**

---

មន្ត្រីដែលមានវត្តមាន ______________ ហត្ថលេខា ______________

កាលបរិច្ឆេទ ______________